**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ...០៤១.........បទ.ប្រក..............

# ប្រកាស
# ស្តីពី
# បញ្ញើហាមឃាត់

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩១៣/ ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពី ការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ របស់រាជរដ្ឋាភិបាលស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពី ការផ្ទេរអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ បច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩/អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពី វិស័យប្រៃសណីយ៍
- បានឃើញប្រកាសលេខ ១៨៣ បទ.ប្រក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ស្តីពី ការដាក់ឱ្យប្រើប្រាស់បទដ្ឋានប្រៃសណីយ៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**ប្រការ១._**

ប្រកាសនេះ មានគោលបំណងផ្សព្វផ្សាយនូវបញ្ជីឈ្មោះវត្ថុបញ្ញើហាមឃាត់ និងទប់ស្កាត់ការផ្ញើវត្ថុបញ្ញើហាមឃាត់តាមសេវាប្រៃសណីយ៍ និងសេវាទទួល ដឹកជញ្ជូន និងចែកចាយបញ្ញើ។



អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

**ប្រការ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការប្រៃសណីយ៍ និងរាល់សកម្មភាពទទួល ដឹកជញ្ជូន និងចែកចាយបញ្ញើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣._**

បណ្តាវត្ថុបញ្ញើដែលត្រូវចាត់ទុកជាប្រភេទបញ្ញើហាមឃាត់មានដូចខាងក្រោមនេះ៖

ក- សម្ភារទាំងឡាយដែលវេចខ្ចប់មិនបានល្អអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ឬធ្វើឱ្យខូចខាតដល់បញ្ញើដទៃទៀត

ខ- គ្រឿងញៀនគ្រប់ប្រភេទ និងប្រភេទទំនិញដទៃទៀតដែលច្បាប់ហាមឃាត់

គ- រូបធាតុដែលអាចផ្ទុះ ងាយឆាបឆេះ ឬរូបធាតុផ្សេងៗទៀតដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់

ឃ- វត្ថុដែលមានភាពអាសអាភាសប៉ះពាល់ដល់សីលធម៌សង្គម និងវត្ថុដែលមានខ្លឹមសារប៉ះពាល់ដល់ច្បាប់រដ្ឋ សន្តិសុខ និងរបៀបរៀបរយសង្គម

ង- សារធាតុធ្វើឱ្យស្រវឹង ឬធ្វើឱ្យឆ្កួតដូចបានកំណត់ដោយគណៈកម្មការត្រួតពិនិត្យសារធាតុញៀនអន្តរជាតិ ឬប្រភេទថ្នាំដទៃទៀតដែលប្រទេសទទួលបានហាមឃាត់

ច- វត្ថុក្លែងក្លាយ និងលួចចម្លងស្នាដៃអ្នកដទៃ

ឆ- ឧបករណ៍ជាតិផ្ទុះ អាវុធយុទ្ធភណ្ឌគ្រប់ប្រភេទ និងវត្ថុប្រហាក់ប្រហែលដែលត្រូវបានហាមឃាត់នៅក្នុងគ្រប់ប្រភេទបញ្ញើ។

ជ- វត្ថុបញ្ញើដែលត្រូវហាមឃាត់ដោយប្រទេសទទួល

ឈ- វត្ថុបញ្ញើទាំងឡាយដែលមានរាយឈ្មោះក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤._**

បណ្តាវត្ថុបញ្ញើដែលត្រូវបានអនុញ្ញាតឱ្យផ្ញើ ប៉ុន្តែត្រូវមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច និងមានការព្រមព្រៀងពីប្រទេសទទួលមានដូចខាងក្រោមនេះ៖

ក- វត្ថុបញ្ញើមានតម្លៃទាំងឡាយដូចមានចែងនៅក្នុងមាត្រា ១៩ នៃច្បាប់ស្តីពី វិស័យប្រៃសណីយ៍

ខ- វត្ថុបញ្ញើជាសត្វមានជីវិតដូចមានចែងនៅក្នុងចំណុចទី ៤ នៃមាត្រា ១៥ របស់អនុសញ្ញាសហភាពប្រៃសណីយ៍សកល (ដូចមានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធ)

គ- វត្ថុបញ្ញើជាសារធាតុវិទ្យុសកម្ម ដូចមានចែងនៅក្នុងមាត្រា ១៣១ នៃពិធីសាចុងក្រោយស្តីពីបទប្បញ្ញត្តិបញ្ញើ សំបុត្រប្រៃសណីយ៍(Letter Post Regulations-Final Protocol) (ដូចមានភ្ជាប់ក្នុងតារាងឧបសម្ព័ន្ធ)

ឃ- វត្ថុបញ្ញើទាំងឡាយដែលមានរាយឈ្មោះនៅក្នុងបញ្ជីរាយនាមមុខទំនិញ និងវត្ថុបញ្ញើដែលត្រូវស្នើសុំការអនុញ្ញាតពីស្ថាប័នពាក់ព័ន្ធ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ)នៃប្រកាសនេះ។

**ប្រការ៥._**

ជនទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ នឹងត្រូវទទួលការពិន័យ ផ្តន្ទាទោសដូចមានចែងក្នុងច្បាប់ស្តីពី វិស័យប្រៃសណីយ៍ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ៦._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គាធិការ ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត អគ្គនាយកប្រៃសណីយ៍កម្ពុជា អគ្គនាយកប្រតិបត្តិករប្រៃសណីយ៍ ប្រធានភ្នាក់ងារប្រៃសណីយ៍ ប្រធានស្ថាប័ន-អង្គភាព និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

-ក្រសួងបរិស្ថាន

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ក្រសួងសុខាភិបាល

-អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

«ដើម្បីជូនជ្រាប»

-ដូចប្រការ ៧«ដើម្បីអនុវត្ត»

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ